ព្រឹត្តិបត្រព័ត៌មាន

NEC BULLETIN

# គ.ជ.ប

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

## ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២

លេខ ០៧ ចេញផ្សាយថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២


គណបក្សប្រជាជនកម្ពុជា
ហែក្បួនឃោសនានៅរាជធានីភ្នំពេញ


គណបក្ស សម រង្ស៊ី
ហែក្បួនឃោសនានៅរាជធានីភ្នំពេញ


គណបក្សហ៊្វុនស៊ិនប៉ិច
ហែក្បួនឃោសនានៅឃុំអូរគ្រៀង ខេត្តក្រចេះ


គណបក្សសិទ្ធិមនុស្ស
ចែកខិត្តប័ណ្ណឃោសនានៅក្រុងព្រៃវែង ខេត្តព្រៃវែង


គណបក្សនរោត្តម រណឫទ្ធិ
ប្រជុំឃោសនានៅឃុំល្វា ខេត្តព្រៃវែង


គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ
ហែក្បួនឃោសនានៅខេត្តព្រៃវែង


គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ
ហែក្បួនឃោសនានៅឃុំព្រែកខ្លោង ខេត្តព្រៃវែង


គណបក្សសញ្ជាតិកម្ពុជា


គណបក្សខ្មែរឈប់ក្រ


គណបក្សចលនាប្រជាធិបតេយ្យ

## មាតិកា

- សន្និសីទសារព័ត៌មានស្តីពីដំណើរការឃោសនាបោះឆ្នោត........ ២
- បទសម្ភាសន៍ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប ........ ៣
- ភ្នាក់ងារនៃគណបក្សនយោបាយចំនួន ១១៨.៨១០នាក់ ......... ១២
- សេចក្តីណែនាំស្តីពីការផ្សព្វផ្សាយ និងការអត្ថាធិប្បាយ........... ១៣
- សេចក្តីណែនាំស្តីពីការផ្អាកមិនឲ្យលក់ដូរ និងពិសារគ្រឿងស្រវឹង.... ១៤



www.necelect.org.kh, www.voterlist.org.kh, Email: necinfo@forum.org.kh, Phone/Fax (023) 214 374

# សន្និសីទសារព័ត៌មានស្តីពីដំណើរការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២

ខណៈពេលដែលការឃោសនាបោះឆ្នោតបានប្រព្រឹត្តទៅអស់រយៈពេល១សប្តាហ៍រួចមក នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប) បានធ្វើសន្និសីទសារព័ត៌មានផ្សព្វផ្សាយអំពីសភាពការណ៍ទូទៅនៃការឃោសនាបោះឆ្នោត និងរំលឹកដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឱ្យគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត។



ឯកឧត្តម សោម ច័ន្ទឌីណា សមាជិក គ.ជ.ប

ឯកឧត្តម សោម ច័ន្ទឌីណា សមាជិក គ.ជ.ប និងជាប្រធានដឹកនាំអង្គសន្និសីទ បានរំលឹកអំពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី ដែលត្រូវអនុវត្តក្នុងការឃោសនាបោះឆ្នោត ។ ឯកឧត្តមបានបន្តថា យើងទាំងអស់គ្នាបានដឹងហើយថា ការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ គឺមានទិសដៅផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួន ហើយនិងបង្ហាញអំពីបេក្ខជនដែលឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ដល់អ្នកបោះឆ្នោត ដើម្បីឱ្យបោះឆ្នោតគាំទ្រ ។ ច្បាប់បានកំណត់ និងចង្អុលទិសដៅដល់គណបក្សនយោបាយ ដើម្បីធ្វើសកម្មភាពឃោសនាស្វែងរកសន្លឹកឆ្នោតពីអ្នកបោះឆ្នោត ក្នុងនោះ ច្បាប់បានផ្តល់ឱ្យមានការជួបជុំជាសាធារណៈ ការហែក្បួនព្យុះហយាត្រា ការចែកខិត្តប័ណ្ណ ការបិទកម្មវិធីនយោបាយ និងការចុះសំណេះសំណាល បង្រៀនប្រជាពលរដ្ឋអ្នកបោះឆ្នោតឱ្យចេះគូសសន្លឹកឆ្នោត និងចាក់ផ្សាយតាមប្រព័ន្ធវីដេអូ ឌីវីឌី ឬចម្រៀងតាមវិទ្យុ រឿងកំប្លែង ។ ឯកឧត្តម សោម ច័ន្ទឌីណា បានបញ្ជាក់ថា ការឃោសនាបោះឆ្នោតនេះមានរយៈពេល ១៥ថ្ងៃ ដែលគិតពីថ្ងៃទី១៨ ខែឧសភា ដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១២ ។ ហើយថ្ងៃទី០២ ខែមិថុនា គឺជាថ្ងៃ**ស** ដែលហាមមិនឱ្យគ្រប់គណបក្សនយោបាយធ្វើសកម្មភាពឃោសនា និងថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ គឺជាថ្ងៃបោះឆ្នោត ហើយគ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយទាំងអស់ ក៏ត្រូវបានបញ្ឈប់ផងដែរ ។



ឯកឧត្តម សោម ច័ន្ទឌីណា បានធ្វើការណែនាំថា គណបក្សនយោបាយដែលកំពុងធ្វើការប្រកួតប្រជែងនីមួយៗ គឺសុទ្ធតែមានគោលដៅដើម្បីឈ្នះ រកសម្លេងគាំទ្រពីប្រជាពលរដ្ឋ ប៉ុន្តែត្រូវយល់ថា គណបក្សត្រូវធ្វើអ្វីៗផ្អែកទៅលើច្បាប់ គោរពច្បាប់ ត្រូវមានភាពចាស់ទុំ

តទៅទំព័រទី ១៥

# បទសម្ភាសន៍ ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប ស្តីពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ នឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២ ។ តាមប្រតិទិន ការបិទផ្សាយលទ្ធផលបោះឆ្នោតនៅការិយាល័យរាប់សន្លឹកឆ្នោតគឺនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២ និងការប្រកាសលទ្ធផលបឋមនៃការបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប) គឺនៅថ្ងៃទី០៣-០៤ ខែមិថុនា ឆ្នាំ២០១២។



ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប

កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានធ្វើបទសម្ភាសន៍មួយទាក់ទងនឹងការបោះឆ្នោត និងការប្រកាសលទ្ធផលនេះ ក្នុងកម្មវិធីស្វែងយល់ពីការបោះឆ្នោត ។ បទសម្ភាសន៍នេះត្រូវបានចាក់ផ្សាយជាសាធារណៈនៅអំឡុងខែឧសភា ឆ្នាំ២០១២ តាមកញ្ចក់ទូរទស្សន៍ជាតិកម្ពុជា វិទ្យុ AM 918KHz និង FM 96MHz ហើយព្រឹត្តិបត្រព័ត៌មាន គ.ជ.ប សូមធ្វើការចុះផ្សាយនូវបទសម្ភាសន៍នេះដូចតទៅ ៖

***សំណួរ ៖ ទាក់ទងនឹងប្រធានបទខាងលើនេះ សូមឯកឧត្តមមានប្រសាសន៍អំពីនីតិវិធី និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣នេះ នៅការិយាល័យបោះឆ្នោត នៅថ្ងៃបោះឆ្នោត តើយ៉ាងដូចម្តេចដែរឯកឧត្តម ?***

ចម្លើយ ៖ មុននឹងជម្រាបជូនអំពីការប្រព្រឹត្តទៅនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត នៅថ្ងៃបោះឆ្នោត ខ្ញុំសូមអនុញ្ញាតជម្រាបជូនជាបឋមនូវបទបញ្ញត្តិទូទៅ និងព័ត៌មានសំខាន់ៗ ដែលទាក់ទងនឹងការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២នេះ ។ ការរៀបចំ ការគ្រប់គ្រងការបោះឆ្នោត ក៏ដូចជាបញ្ជីបោះឆ្នោត ត្រូវបានច្បាប់ផ្តល់សមត្ថកិច្ចដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប) ជាអ្នករៀបចំ។ ឃុំ សង្កាត់ទាំងអស់ត្រូវមានក្រុមប្រឹក្សាឃុំ សង្កាត់មួយដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់នោះ តាមការបោះឆ្នោតជាទូទៅជាសកល ដោយសេរី ដោយត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ និងដោយសម្ងាត់ ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងអស់ត្រូវធ្វើឡើងរៀងរាល់ ៥ឆ្នាំម្តង តាមប្រព័ន្ធសមាមាត្រដោយបែងចែកអាសនៈតាមរូបមន្តមធ្យមភាគខ្ពស់បំផុត យកឃុំ សង្កាត់ជាមណ្ឌលបោះឆ្នោត ។ ដើម្បីមានសិទ្ធិបោះឆ្នោតប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានឯកសារបញ្ជាក់អត្តសញ្ញាណ ។ បញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នេះ ត្រូវយកបញ្ជីបោះឆ្នោតចុងក្រោយ ដែលត្រូវបានផ្តល់សុពលភាពដោយ គ.ជ.ប ទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើស

តាំងតំណាងរាស្ត្រ ។ សម្រាប់ការបោះឆ្នោតនេះបញ្ជីបោះឆ្នោតចុងក្រោយ គឺជាបញ្ជីបោះឆ្នោត ឆ្នាំ២០១១ ដែល គ.ជ.ប បានផ្តល់សុពលភាពនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១កន្លងមក ដែលមានឈ្មោះអ្នកបោះឆ្នោតសរុបប្រមាណជា **៩.២០៣.៤៩៣**នាក់ និងការិយាល័យបោះឆ្នោត **១៨.១០៧**ការិយាល័យ ។ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិទី៣នេះ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់មានចំនួន **១១.៤៥៩** នាក់ ដែលលើសពីអាណត្តិមុនចំនួន **១០៦**នាក់ ហើយឃុំ សង្កាត់ក៏បានកើនឡើងរហូតដល់ **១.៦៣៣** ក្នុងនោះមានឃុំ សង្កាត់បង្កើតថ្មីចំនួន **១២** ។ ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតបានចាប់ផ្តើមពីថ្ងៃទី០១ ដល់ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១២ ជាលទ្ធផលមានគណបក្សនយោបាយចំនួន ១០ បានចុះបញ្ជី ហើយមានបេក្ខជនសរុបប្រមាណចំនួន **១១១.០៥៦**នាក់ ។ សម្រាប់ការបោះឆ្នោតនេះដែរ សន្លឹកឆ្នោតពីឃុំ សង្កាត់មួយទៅឃុំ សង្កាត់មួយគឺខុសគ្នា ទាំងទំហំ ទាំងចំនួនគណបក្ស និងទាំងលេខរៀងគណបក្ស គឺមិនដូចគ្នានឹងលេខរៀងគណបក្សនៅលើសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ ពីព្រោះថា វាអាស្រ័យដោយចំនួនគណបក្សដែលឈរឈ្មោះនៅក្នុងឃុំ សង្កាត់នីមួយៗ និងអាស្រ័យដោយការចាប់ឆ្នោតកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយលើសន្លឹកឆ្នោតនៅតាមឃុំ សង្កាត់នីមួយៗ ។

ខ្ញុំសូមជម្រាបជូនដែរថា រចនាសម្ព័ន្ធ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នេះ នៅជំណាក់កាលបោះឆ្នោត គឺមាន គ.ជ.ប ដែលមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ នៅរាជធានី ខេត្តនីមួយៗ មានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត(គជ/ខប) នៅឃុំ សង្កាត់នីមួយៗមានគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត(គឃ/សប) និងនៅការិយាល័យបោះឆ្នោតមានមន្ត្រីគណៈកម្មការការិយាល័យបោះឆ្នោត(គកប) ។ នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នេះ គឃ/សប មានតួនាទីសំខាន់ណាស់ ទាំងក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ទាំងក្នុងការបោះឆ្នោត រាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលនៃការបោះឆ្នោត ហើយក្នុងនោះសំខាន់ទៀត គឺការសម្របសម្រួលដំណើរការឃោសនាបោះឆ្នោតដែលមានរយៈពេល ១៥ថ្ងៃ ហើយនឹងត្រូវបញ្ចប់វិញក្នុងរយៈពេល ២៤ម៉ោង មុនថ្ងៃបោះឆ្នោត ។ ចំពោះនីតិវិធី និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ខ្ញុំគិតថា បើយើងនិយាយពីនីតិវិធីដូចជាវាលម្អិតពេក អញ្ចឹងទេ ខ្ញុំសូមជូនជាគោលការណ៍សំខាន់ៗ និងរបៀបនៃការបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

ជាដំបូងខ្ញុំសូមជម្រាបនូវចំណុចសំខាន់បួនដែលត្រូវដឹង និងអនុវត្តនៅក្នុងការិយាល័យបោះឆ្នោត **ទី១** អំពីតួអង្គសំខាន់ៗដែលត្រូវមានវត្តមាននៅការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត **ទី២** អំពីការរៀបចំ និងការបើកការិយាល័យបោះឆ្នោត **ទី៣** ការប្រព្រឹត្តទៅនៃការបោះឆ្នោត និង**ទី៤** អំពីការបិទការបោះឆ្នោត ។

១- តួអង្គសំខាន់ៗ នៅក្នុងការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត **ទី១** គឺគណៈកម្មការការិយាល័យបោះឆ្នោតដែលមានប្រធានមួយរូប អនុប្រធានមួយរូប លេខាធិការមួយរូប ជំនួយការពីររូប និងមន្ត្រីទទួលបន្ទុកសណ្តាប់ធ្នាប់ការិយាល័យបោះឆ្នោតមួយរូប **ទី២** គឺភ្នាក់ងារសន្តិសុខបោះឆ្នោត ដែលមានពាក់ប្រឡង់ដៃដែលផ្តល់ដោយ គ.ជ.ប គាត់មានភារកិច្ចការពារសន្តិសុខ សុវត្ថិភាពការិយាល័យបោះឆ្នោតនៅបរិវេណជុំវិញការិយាល័យបោះឆ្នោត ក្នុងរង្វង់ចម្ងាយពី ១៥ម៉ែត្រ ទៅ ១៥០ម៉ែត្រ ទៅតាមស្ថានភាពជាក់ស្តែង នៃការិយាល័យបោះឆ្នោតនីមួយៗ **ទី៣** គឺភ្នាក់ងារសង្កេតការណ៍របស់គណបក្សនយោបាយនីមួយៗ ក្នុងគណបក្សនីមួយៗ



គំនូសទំហំនៃបរិវេណខាងក្នុង និងបរិវេណខាងក្រៅ នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

គំនូសប្រព័ន្ធការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

មានភ្នាក់ងារម្នាក់ៗ តាមការអនុញ្ញាតរបស់ គឃ/សប គឺគណបក្សដែលឈរឈ្មោះក្នុងឃុំ សង្កាត់នោះ ភ្នាក់ងារគណបក្សនេះ គាត់មានសិទ្ធិសង្កេតមើលដំណើរការនៃការបោះឆ្នោត រាប់សន្លឹកឆ្នោត នៅក្នុងការិយាល័យបោះឆ្នោត ហើយគាត់ក៏មានសិទ្ធិសំណូមពរ ឬជំទាស់ទៅប្រធានការិយាល័យបោះឆ្នោតផ្ទាល់ ដើម្បីឱ្យដោះស្រាយបញ្ហាមិនប្រក្រតី ដែលគាត់ឃើញមាននៅក្នុងការិយាល័យបោះឆ្នោត។ ហើយបន្ទាប់មកទៀត **ទី៤** គឺមានអ្នកសង្កេតការណ៍ការបោះឆ្នោត ដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប អ្នកសង្កេតការណ៍បោះឆ្នោតនេះ គាត់មានសិទ្ធិសង្កេតមើលដំណើរការនៃការបោះឆ្នោត រាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ក៏ប៉ុន្តែគាត់ពុំមានសិទ្ធិសំណូមពរ ឬក៏តវ៉ាចំពោះប្រធានការិយាល័យបោះឆ្នោត ដូចភ្នាក់ងារគណបក្សនយោបាយទេ ជាមួយនោះ **ទី៥** ក៏មានអ្នកយកព័ត៌មានដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប និងត្រូវបានអនុញ្ញាតឱ្យចូលយកព័ត៌មានក្នុងការិយាល័យបោះឆ្នោតដោយប្រធានការិយាល័យបោះឆ្នោត ហើយ **ទី៦** ចុងក្រោយបំផុតសំខាន់ គឺអ្នកបោះឆ្នោតដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។

២- អំពីការរៀបចំការិយាល័យបោះឆ្នោត នៅមុនពេលបើកការបោះឆ្នោត ជាធម្មតា គគប គាត់ត្រូវរៀបចំការិយាល័យបោះឆ្នោតនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត ទាំងការធ្វើអនាម័យ ការរៀបចំទីកន្លែង ហើយព្រមទាំងការបិទផ្សាយបញ្ជីបោះឆ្នោតនៅក្នុងការិយាល័យនោះ ដើម្បីឱ្យប្រជាពលរដ្ឋបានទៅពិនិត្យមើលឈ្មោះរបស់ខ្លួននៅមុនថ្ងៃបោះឆ្នោត ។ ហើយនៅថ្ងៃបោះឆ្នោត គឺនៅព្រឹកឡើងសមាសភាពការិយាល័យទាំងអស់ត្រូវតែមានវត្តមាននៅការិយាល័យបោះឆ្នោតនៅវេលាម៉ោង ៦ព្រឹក ។ បន្ទាប់មកគាត់ត្រូវរៀបចំការិយាល័យបោះឆ្នោតទៅតាមគំរូប្លង់



គំរូប្លង់ការិយាល័យបោះឆ្នោត

ដែលផ្តល់ដោយ គ.ជ.ប ។ ប្រធានការិយាល័យបោះឆ្នោតត្រូវប្រកាសឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ព្រមទាំងអ្នកយកព័ត៌មាន(ប្រសិនបើមាន) ចូលទៅក្នុងការិយាល័យបោះឆ្នោត ដើម្បីគាត់ត្រួតពិនិត្យមើលឯកសារអនុញ្ញាតឱ្យចូលសង្កេតមើល ឬចូលយកព័ត៌មានក្នុងការិយាល័យបោះឆ្នោត ហើយព្រមទាំងណែនាំពីបទបញ្ជានៅក្នុងការិយាល័យបោះឆ្នោត និងបង្ហាញពីទីកន្លែងដែលគាត់ត្រូវឈរសង្កេតមើលដំណើរការបោះឆ្នោត ។ ប្រធានការិយាល័យបោះឆ្នោតត្រូវដឹកនាំអំពីការត្រួតពិនិត្យសម្ភារឯកសារសម្រាប់បម្រើការបោះឆ្នោត ក៏ដូចជារាប់សន្លឹកឆ្នោត ការងារនេះត្រូវអនុវត្តនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ក៏ដូចអ្នកសារព័ត៌មាននៅទីនោះទាំងអស់ ។ ទី១ គាត់ត្រូវបង្ហាញអំពីហិបឆ្នោត គាត់ត្រូវត្រួតពិនិត្យហិប



ប្រធាន គកប បង្ហាញហិបឆ្នោតទទេដល់សមាជិក គកប ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

ឆ្នោតមើល តើបានតម្លើងត្រឹមត្រូវទេ ? គាត់បើកគម្រប ហិបឆ្នោត បង្ហាញហិបឆ្នោតទទេទៅអ្នកសង្កេតការណ៍ នៅទីនោះទាំងអស់ ហើយបន្ទាប់មក គាត់បិទគម្របខាង ក្នុងនៃហិបឆ្នោតនេះវិញ ដោយចាក់សោរឃុំមានលេខ ហើយគាត់ត្រូវចុះហត្ថលេខា និងកត់លេខកូដការិយាល័យ បោះឆ្នោតនៅលើក្រដាសពីរសន្លឹកទៅបិទនៅជញ្ជាំងសង




សោរឃុំមានលេខដែលប្រធានចាក់ភ្ជាប់ត្រង់ពង្រឹះគម្របក្នុងនៃហិបឆ្នោត

ខាងនៃហិបឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតនោះ ។ ទី២ ប្រធានការិយាល័យបោះឆ្នោតត្រូវចាត់ឱ្យអនុប្រធាន ការិយាល័យបោះឆ្នោតត្រួតពិនិត្យមើលសន្លឹកឆ្នោតនៅ ក្នុងកញ្ចប់ហ្នឹង តើជាសន្លឹកឆ្នោតរបស់ការិយាល័យបោះ ឆ្នោតនេះមែនឬទេ ? ក្នុងករណីត្រឹមត្រូវហើយ អនុប្រធាន ការិយាល័យបោះឆ្នោតត្រូវរាប់សន្លឹកឆ្នោតនៅក្នុងជុំទាំង មូល ហើយផ្ទៀងផ្ទាត់មើលចំនួនសន្លឹកឆ្នោត ជាធម្មតា ចំនួនសន្លឹកឆ្នោតនេះមានចំនួនលើសឈ្មោះអ្នកបោះឆ្នោត នៅក្នុងការិយាល័យបោះឆ្នោតពី ៥០សន្លឹក ទៅ ៩៩ សន្លឹក ។ ទី៣ គាត់ត្រូវត្រួតពិនិត្យមើលត្រាសម្ងាត់ ប្រធាន ការិយាល័យបោះឆ្នោតត្រូវបើកកញ្ចប់ត្រាសម្ងាត់ត្រួត ពិនិត្យមើល ហើយបោះត្រាសម្ងាត់នេះលើក្រដាសស មួយសន្លឹក រួចលើកបង្ហាញភ្នាក់ងារសង្កេតការណ៍ទាំង អស់ឱ្យបានឃើញ និងចំណាំនូវរូបនៅក្នុងត្រាសម្ងាត់ ។ ត្រាសម្ងាត់នេះសម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត។ ហើយ សូមជម្រាបដែរថា នៅក្នុងការិយាល័យបោះឆ្នោតមាន ត្រាពីរ ទី១ គឺត្រា គកប ដែលជាត្រារដ្ឋបាល ហើយទី២ ត្រាសម្ងាត់ គឺជាត្រាដែលសម្រាប់បោះលើខ្នងសន្លឹកឆ្នោត។ ចុងក្រោយបំផុត ប្រធានការិយាល័យបោះឆ្នោតត្រូវដឹក នាំការត្រួតពិនិត្យឯកសារផ្សេងទៀត ក្នុងនោះសំខាន់មាន បញ្ជីបោះឆ្នោត បន្ទប់សម្ងាត់សម្រាប់ចូលគូសសន្លឹកឆ្នោត ទឹកខ្មៅលុបលាងមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃក្រោយ ពេលបោះឆ្នោត ហើយព្រមទាំងសម្ភារឯកសារសម្រាប់ បម្រើឱ្យការរាប់សន្លឹកឆ្នោត ។

សូមជម្រាបថា រាល់ការអនុវត្តទាំងអស់នេះ គឺ ត្រូវធ្វើនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ ក៏ ដូចជាអ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន នៅទីនោះ ហើយលេខាធិការត្រូវកត់ត្រារាល់សកម្មភាព ទាំងអស់ទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

៣- អំពីការប្រព្រឹត្តទៅនៃការបោះឆ្នោត នៅវេលា ម៉ោងប្រាំពីរ( ៧:០០)ព្រឹក ប្រធានការិយាល័យបោះឆ្នោត ត្រូវប្រកាសបើកការបោះឆ្នោត ក្នុងនោះជាបឋមគាត់ ត្រូវអញ្ជើញសមាជិកគណៈកម្មការការិយាល័យបោះ ឆ្នោតដែលមានឈ្មោះក្នុងការិយាល័យនោះបោះឆ្នោត មុន ហើយបន្ទាប់មកអញ្ជើញតំណាងគណបក្សនយោ បាយដែលមានឈ្មោះនៅក្នុងការិយាល័យនោះបោះ ឆ្នោត ។ សូមជម្រាបថា នៅក្នុងដំណាក់កាលនេះ ជំនួយ ការទីពីរដែលនៅខាងក្រៅការិយាល័យបោះឆ្នោត គាត់ មានភារកិច្ចជួយមើលឈ្មោះអ្នកបោះឆ្នោត និងជួយរៀប

ចំសណ្តាប់ធ្នាប់ ដោយអញ្ជើញអ្នកបោះឆ្នោតនៅខាងក្រៅឱ្យតម្រង់ជាជួរ ហើយមន្ត្រីទទួលបន្ទុកសណ្តាប់ធ្នាប់នៃការិយាល័យបោះឆ្នោត ជាដំបូងគាត់ត្រូវអញ្ជើញអ្នកបោះឆ្នោត ៤រូប ឱ្យចូលទៅបោះឆ្នោត ។ បន្ទាប់មកក្រោយពីមានអ្នកបោះឆ្នោតចេញពីការិយាល័យបោះឆ្នោត គាត់អាចអញ្ជើញអ្នកបោះឆ្នោតឱ្យចូលជាបន្តបន្ទាប់ទៀត ដោយរក្សាអ្នកបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតយ៉ាងច្រើន ៤នាក់ នៅក្នុងការិយាល័យ ។ ដើម្បីបានបោះឆ្នោត អ្នកបោះឆ្នោតត្រូវមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត និងមានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត ។ នៅពេលចូលទៅក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតត្រូវអនុវត្តតាមសង្វាក់ការងារនៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត ។ ជាបឋមគាត់ត្រូវជួបនឹងលេខាធិការនៃការិយាល័យបោះឆ្នោត ដោយគាត់ត្រូវបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណទៅលេខាធិការ ដើម្បីលេខាធិការផ្ទៀងផ្ទាត់ ហើយអនុញ្ញាតឱ្យលេខាធិការផ្ទៀងផ្ទាត់ម្រាមដៃរបស់គាត់ តើមានប្រឡាក់ទឹកខ្មៅលុបលាងមិនជ្រះទេ ក្នុងករណីថា ម្រាមដៃរបស់គាត់ស្អាត លេខាធិការត្រូវត្រួតពិនិត្យមើលទិន្នន័យនៅក្នុងបញ្ជីបោះឆ្នោតជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណផ្ទៀងផ្ទាត់មុខរបស់គាត់ជាមួយនឹងរូបថត ហើយក្នុងករណីត្រឹមត្រូវហើយ លេខាធិការអញ្ជើញគាត់ជួបអនុប្រធានការិយាល័យបោះឆ្នោត ដោយបញ្ជូនឯកសារបញ្ជាក់អត្តសញ្ញាណនេះទៅអនុប្រធានការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតត្រូវទៅជួបអនុប្រធានការិយាល័យបោះឆ្នោត អនុប្រធានការិយាល័យបោះឆ្នោតនឹងហែកសន្លឹកឆ្នោតព្រមទាំងបោះត្រាសម្ងាត់នៅលើខ្នងសន្លឹកឆ្នោត ហើយបត់ជាបួនផ្តត់បង្ហាញអ្នកបោះឆ្នោតអំពីរបៀបបត់ និងណែនាំអ្នកបោះឆ្នោតអំពីការគូសសន្លឹកឆ្នោត ការបត់សន្លឹកឆ្នោតឡើងវិញ និងការបោះឆ្នោត ។ រួចមកគាត់ណែនាំអ្នកបោះឆ្នោតឱ្យចូលទៅក្នុងបន្ទប់សម្ងាត់ដើម្បីគូសបោះឆ្នោត ។ អ្នកបោះឆ្នោតត្រូវអញ្ជើញទៅបន្ទប់សម្ងាត់តាមការណែនាំរបស់អនុប្រធានការិយាល័យបោះឆ្នោត ហើយគាត់អាចប្រើប៊ិចនៅក្នុងបន្ទប់សម្ងាត់នោះដើម្បីគូសសន្លឹកឆ្នោត តែមិនអនុញ្ញាតឱ្យប្រើខ្មៅដៃទេ ។ នៅពេលគាត់គូសសន្លឹកឆ្នោតនៅលើប្រអប់បួនជ្រុងនៃគណបក្សនយោបាយដែលគាត់ពេញចិត្តហើយ គាត់ត្រូវបត់សន្លឹកឆ្នោតនោះទៅតាមគំរូដើមវិញ ហើយគាត់អញ្ជើញទៅកាន់ហិបឆ្នោត ។ នៅមុខហិបឆ្នោតដែលមានជំនួយការទី១ នៅទីនោះគាត់ត្រូវបង្ហាញខ្នងសន្លឹកឆ្នោតដែលមានបោះត្រាសម្ងាត់ ហើយស៊កសន្លឹកឆ្នោតដាក់ទៅក្នុងហិបឆ្នោត បន្ទាប់មកគាត់ត្រូវជ្រលក់ម្រាមដៃទៅក្នុងដបទឹកខ្មៅលុបលាងមិនជ្រះ ហើយចុងក្រោយ គាត់អញ្ជើញចេញពីការិយាល័យបោះឆ្នោត ។ នេះជាដំណើរការនៃការបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ។

សូមជម្រាបថា ប្រសិនបើអ្នកមានឈ្មោះក្នុងការិយាល័យបោះឆ្នោត បានបោះឆ្នោតចប់អស់ហើយនៅមុនម៉ោង ៣រសៀល ការិយាល័យបោះឆ្នោតនោះអាចបិទការបោះឆ្នោតបាន ក៏ប៉ុន្តែនៅពេលដល់ម៉ោង ៣រសៀលហើយ នៅមាននៅសល់អ្នកបោះឆ្នោតនៅឈរតម្រង់ជួរ ឬមានអ្នកបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតនៅឡើយ ការិយាល័យនោះអាចបិទបានលុះត្រាតែអ្នកបោះឆ្នោតទាំងអស់នោះបានបោះឆ្នោតហើយ ។

៤- អំពីការបិទការបោះឆ្នោត ក្រោយពីអ្នកបោះឆ្នោតចុងក្រោយបានបញ្ចប់ការបោះឆ្នោតហើយ ប្រធានការិយាល័យបោះឆ្នោតត្រូវប្រកាសបិទការបោះឆ្នោត ក្នុងនោះគាត់ត្រូវដឹកនាំអនុវត្តនូវនីតិវិធីមួយចំនួន ដែលសំខាន់គាត់ត្រូវមួលភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរ ហើយបិទក្រដាសស្តើងដែលមានចុះហត្ថលេខាពីលើ គាត់អាចអញ្ជើញតំណាងគណបក្សចុះហត្ថលេខាលើក្រដាសនេះបាន ហើយបន្ទាប់មកបិទគម្របហិប

ឆ្នោតខាងក្រៅ ដោយមានចាក់សោរឃុំមានលេខពីលើ បន្ទាប់មកគាត់ណែនាំអនុប្រធានដើម្បីឱ្យផ្ទៀងផ្ទាត់សន្លឹកឆ្នោតដែលបានប្រើ មិនបានប្រើ ខូច ហើយនិងណែនាំលេខាធិការឱ្យរាប់ចំនួនអ្នកបោះឆ្នោត ដោយផ្អែកទៅលើចំនួនធីក(√)ឈ្មោះអ្នកបោះឆ្នោតនៅលើបញ្ជីបោះឆ្នោត ។ ក្រោយពីការរាប់សន្លឹកឆ្នោតរបស់អនុប្រធាន និងលេខាធិការហើយ គាត់ត្រូវណែនាំឱ្យធ្វើការផ្ទៀងផ្ទាត់នូវតួលេខទាំងពីរនេះ តើវាស៊ីគ្នាដែរឬទេ ? ហើយជាមួយនោះ គាត់ក៏ត្រូវណែនាំជំនួយការទី២ ដើម្បីឱ្យចោះសន្លឹកឆ្នោតដែលមិនបានប្រើដើម្បីធ្វើមោឃភាពសន្លឹកឆ្នោតនោះ ។ កំណត់ហេតុនៃការបោះឆ្នោត គឺលេខាធិការត្រូវបំពេញជាបន្តបន្ទាប់ទៅតាមដំណើរការនៃការរៀបចំការបោះឆ្នោត រហូតដល់ចប់ការបោះឆ្នោត។ ហើយនៅពេលដែលបំពេញឯកសារកំណត់ហេតុចប់ហើយ លេខាធិការត្រូវចុះហត្ថលេខា និងអញ្ជើញប្រធានការិយាល័យបោះឆ្នោតនេះចុះហត្ថលេខា ព្រមទាំងបោះត្រា ហើយប្រធានការិយាល័យបោះឆ្នោតអាចអញ្ជើញភ្នាក់ងារគណបក្សចូលរួមចុះហត្ថលេខានៅលើកំណត់ហេតុនេះ ក្នុងករណីគាត់យល់ព្រម ។ នេះជាដំណើរការនៃការបើកការបោះឆ្នោតរហូតដល់ការបិទការបោះឆ្នោត ។

***សំណួរ ៖ សូមជម្រាបសួរឯកឧត្តមពីការរាប់សន្លឹកឆ្នោតវិញម្តង ចុះនីតិវិធី និងការប្រព្រឹត្តទៅនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត តើប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរឯកឧត្តម ?***

ចម្លើយ ៖ បន្ទាប់ពីការបិទការបោះឆ្នោត ប្រធានការិយាល័យបោះឆ្នោតត្រូវដឹកនាំការរៀបចំការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះភ្លាមតែម្តង ។ ក្នុងការរៀបចំនេះ ក៏ត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំការិយាល័យរាប់សន្លឹកឆ្នោតទៅតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប ។ ក្នុងការរាប់សន្លឹកឆ្នោត គាត់ត្រូវយកចិត្ត




ទុកដាក់ក្នុងការផ្តល់សុពលភាពលើសន្លឹកឆ្នោត និងការកំណត់ជាសន្លឹកឆ្នោតបានការ ឬមិនបានការ ។ អំពីការរៀបចំការិយាល័យរាប់សន្លឹកឆ្នោត ត្រូវផ្អែកជាសំខាន់លើស្ថានភាពជាក់ស្តែងរបស់ការិយាល័យ ប្រសិនបើមានតុធំវែងមួយ ឬក៏មានតុតូចៗ អាចតម្រៀបចូលគ្នានៅចំកណ្តាលការិយាល័យរាប់សន្លឹកឆ្នោត ហើយត្រូវរៀបចំឱ្យមានកៅអីអង្គុយនៅជ្រុងម្ខាងម្នាក់រវាងប្រធានការិយាល័យបោះឆ្នោត និងលេខាធិការ ដែលគាត់ត្រូវអង្គុយទល់មុខគ្នា ហើយនៅសងខាងតុត្រូវរៀបចំកៅអីសម្រាប់អនុប្រធាន និងជំនួយការទី១ ដែលគាត់ត្រូវអង្គុយទល់មុខគ្នា ។ ក្នុងការរៀបចំការិយាល័យរាប់សន្លឹកឆ្នោតនេះ គាត់ត្រូវតែបង្កលក្ខណៈងាយស្រួលដល់ភ្នាក់ងារគណបក្សនយោបាយ ក៏ដូចជាអ្នកសង្កេតការណ៍បោះឆ្នោត ដែលគាត់អាចដើរចុះឡើងជុំវិញតុរាប់សន្លឹកឆ្នោតនេះ ដើម្បីសង្កេតមើលដំណើរការនៃការរាប់សន្លឹកឆ្នោត ។ ជាបន្ត ប្រធានត្រូវបើកហិបឆ្នោតដែលគាត់បានរក្សាទុកយ៉ាងត្រឹមត្រូវ និងប្រកបដោយសុវត្ថិភាព



បន្ទាប់ពីបញ្ចប់ការបោះឆ្នោត ។ ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវចាក់សន្លឹកឆ្នោតនេះទៅលើតុរាប់សន្លឹកឆ្នោត ប្រធានត្រូវណែនាំអនុប្រធាន និងជំនួយការឱ្យលាសន្លឹកឆ្នោតតម្រៀបនៅលើតុរាប់សន្លឹកឆ្នោត ដោយដាក់ផ្កាប់ចុះក្រោម ។ ដំបូងត្រូវរៀបចំសន្លឹកឆ្នោតដែលមានត្រាសម្គាល់នៅខាងខ្នងដាក់មួយពំនូក នៅក្នុងពំនូកទី១ ដែលរៀបជាបាច់ ក្នុងមួយបាច់មាន ២៥សន្លឹក ហើយនិងរៀបចំនៅក្នុងពំនូកទី២ នូវសន្លឹកឆ្នោតដែលពុំមានត្រាសម្គាល់នៅខាងខ្នង ដែលយើងហៅថា សន្លឹកឆ្នោតមិនបានការ (ប្រសិនបើមាន) ។ បន្ទាប់ពីការរៀបសន្លឹកឆ្នោតទាំងអស់នេះហើយ គាត់ធ្វើការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតនេះទៅតាមរូបមន្តដែលបានកំណត់ដោយ គ.ជ.ប ហើយបន្ទាប់មកគឺការរាប់សន្លឹកឆ្នោត ។ ក្នុងការរាប់សន្លឹកឆ្នោតនេះ ប្រធានត្រូវយកចិត្តទុកដាក់ជាសំខាន់លើសុពលភាពនៃសន្លឹកឆ្នោត គឺគាត់ត្រូវយកសន្លឹកឆ្នោតពីពំនូកទី១ ដែលជាសន្លឹកឆ្នោតបានការ ឬថាជាសន្លឹកឆ្នោតដែលមានត្រាសម្គាល់នៅខាងខ្នងហ្នឹងមួយសន្លឹកម្តងៗ រហូតដល់អស់ពីក្នុងពំនូកទី១នេះ ។ ក្នុងការលើកយកសន្លឹកឆ្នោតនេះ គាត់ត្រូវពិនិត្យទី១អំពីសុពលភាពនៃសន្លឹកឆ្នោត ហើយនៅពេលដែលគាត់ឃើញថា សន្លឹកឆ្នោតហ្នឹងមានសុពលភាពត្រឹមត្រូវហើយ គាត់មើលការគូសគាំទ្ររបស់អ្នកបោះឆ្នោតនៅលើសន្លឹកឆ្នោតនោះ ក្នុងករណីដែលមានការគូសត្រឹមត្រូវហើយ គាត់ត្រូវប្រកាសអំពីគណបក្សនយោបាយដែលអ្នកបោះឆ្នោតបានគូសគាំទ្រ ហើយគាត់លើកសន្លឹកឆ្នោតនេះ បង្ហាញទៅភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍បានមើលអំពីសន្លឹកឆ្នោតនោះ គាត់អាចបង្ហាញទៅគណបក្សនយោបាយទាំងនោះ តែមិនអនុញ្ញាតឱ្យប៉ះពាល់សន្លឹកឆ្នោតទេ ។ ហើយបន្ទាប់មកគាត់ត្រូវណែនាំទៅអនុប្រធាន លេខាធិការ ឱ្យកត់ត្រាលទ្ធផលនៃការបោះឆ្នោតនេះ នៅលើទម្រង់កត់លទ្ធផលនៃការបោះឆ្នោត និងណែនាំជំនួយការទី១ ឱ្យគូសលទ្ធផលនេះនៅលើក្រដាសគូសសន្លឹកឆ្នោតដែលបិទនៅលើក្តារខៀន ឬក៏នៅជញ្ជាំងក្បែរនោះ បង្ហាញនៅចំពោះមុខគណបក្ស



នយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលដែលមានវត្តមាននៅទីនោះ ។ បន្ទាប់ពីការកត់ត្រានេះ ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវប្រកាសអំពីឈ្មោះគណបក្សដែលត្រូវបានគូសសន្លឹកឆ្នោតគាំទ្រនេះឱ្យឮដល់អ្នកមានវត្តមាននៅទីនោះ ហើយក្នុងករណីដែលមានសន្លឹកឆ្នោតមិនបានការ គាត់ក៏ត្រូវប្រកាសឱ្យឮៗដល់អ្នកដែលមានវត្តមាននៅទីនោះ អំពីមូលហេតុដែលគាត់ចាត់ទុកថា សន្លឹកឆ្នោតនេះជាសន្លឹកឆ្នោតមិនបានការ ។ ហើយក្នុងដំណើរការនៃការរាប់សន្លឹកឆ្នោតនេះ ប្រសិនបើមានការជំទាស់ពីភ្នាក់ងារគណបក្សនយោបាយ គាត់ត្រូវយកសន្លឹកឆ្នោតនេះដាក់ទៅក្នុងពំនូកសន្លឹកឆ្នោតទី២ ដែលជាសន្លឹកឆ្នោតមិនបានការ ។ ហើយពំនូកទី២នេះ គាត់ត្រូវធ្វើការផ្តល់សុពលភាពជាលើកចុងក្រោយម្តងទៀត ដូចជាការអនុវត្តនៅក្នុងពំនូកទី១ដែរ គឺគាត់ត្រូវយកម្តងមួយៗពិនិត្យឡើងវិញ ហើយសម្រេចលើសន្លឹកឆ្នោតនេះ ហើយក្នុងករណីដែលមានការតវ៉ា គាត់មានឆន្ទានុសិទ្ធិក្នុងការសម្រេចនៅក្នុងពេលរាប់សន្លឹកឆ្នោតនេះ។ ក្រោយពីការរាប់សន្លឹកឆ្នោត ប្រធានត្រូវចាត់ឱ្យអនុប្រធាន លេខាធិការ ក៏ដូចជាជំនួយការទី១ ធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោត គឺសន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោតគាំទ្រ

គណបក្សនយោបាយ សន្លឹកឆ្នោតខូច ហើយបន្ទាប់មក គាត់ធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។ ជាចុងក្រោយគាត់ត្រូវរៀបចំធ្វើការវេចខ្ចប់សម្ភារការិយាល័យបោះឆ្នោត ឯកសារបោះឆ្នោត ដើម្បីត្រៀមបញ្ជូនទៅ គឃ/សប នៅល្ងាចថ្ងៃបោះឆ្នោតនោះតែម្តង ។ រាល់សកម្មភាពទាំងអស់នេះ គាត់ត្រូវធ្វើនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ គាត់ត្រូវឱ្យលេខាធិការកត់ត្រាបំពេញនៅក្នុងទម្រង់នៃការរាប់សន្លឹកឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត គាត់ត្រូវចុះហត្ថលេខា បោះត្រា និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាននៅទីនោះ ឱ្យចុះហត្ថលេខាដើម្បីជាសាក្សី ក្នុងករណីដែលភ្នាក់ងារទាំងអស់នោះយល់ព្រម ។ ហើយចុងបញ្ចប់ គាត់ត្រូវបញ្ជូនសម្ភារទាំងអស់នោះទៅ គឃ/សប គាត់អាចអញ្ជើញភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍ ដើម្បីរួមដំណើរបញ្ជូនសម្ភារទាំងអស់នេះទៅ គឃ/សប ជាមួយដែរ ។

***សំណួរ ៖ ចំពោះការប្រកាសលទ្ធផលនៃការបោះឆ្នោតវិញ តើលទ្ធផលផ្លូវការនឹងប្រកាសចេញនៅពេលណាដែរ ?***

ចម្លើយ ៖ ចំពោះលទ្ធផលផ្លូវការនៃការបោះឆ្នោត គឺអាស្រ័យទៅនឹងករណីគ្មាន ឬមានពាក្យបណ្តឹង ក្នុងករណីគ្មានពាក្យបណ្តឹង យើងអាចប្រកាសលទ្ធផលផ្លូវការយ៉ាងយូរមួយសប្តាហ៍បន្ទាប់ពីថ្ងៃបោះឆ្នោត ហើយក្នុងករណីមានពាក្យបណ្តឹង គឺលទ្ធផលផ្លូវការនឹងអាចចេញរហូតដល់ថ្ងៃចុងក្រោយក្នុងរយៈពេលបីសប្តាហ៍បន្ទាប់ពីថ្ងៃបោះឆ្នោត ។

ចំពោះការចេញលទ្ធផលនេះយើងមានដំណាក់កាលទៅតាមថ្នាក់នីមួយៗ គឺនៅថ្ងៃបោះឆ្នោត នៅការិយាល័យរាប់សន្លឹកឆ្នោត បន្ទាប់ពីការរាប់សន្លឹកឆ្នោត ប្រធានត្រូវប្រកាសដោយផ្ទាល់មាត់នៅការិយាល័យបោះឆ្នោតអំពីលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅទីនោះ ហើយបន្ទាប់មកគាត់ចាត់ឱ្យលេខាធិការ ជំនួយការទី២ យកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ដែលនៅក្នុងនោះមានលទ្ធផលនៃការបោះឆ្នោតផង ទៅបិទនៅច្រកចូលនៃការិយាល័យរាប់សន្លឹកឆ្នោត ហើយគាត់ចាត់តាំងឱ្យសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត បំពេញក្រដាសលទ្ធផលនៃការបោះឆ្នោត ដើម្បីចែកជូនភ្នាក់ងារគណបក្សនយោបាយនៅទីនោះ អំពីលទ្ធផលនៃការបោះឆ្នោតនេះ នៅការិយាល័យបោះឆ្នោត។ ដោយឡែកនៅ គឃ/សប ក្រោយពីទទួលបានសម្ភារឯកសារពីការិយាល័យបោះឆ្នោត គឃ/សប ត្រូវធ្វើការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងរយៈពេល ៣ថ្ងៃ ហើយបន្ទាប់មក គាត់បិទលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំសង្កាត់របស់ខ្លួន ដើម្បីឱ្យធ្វើការតវ៉ា ។ នេះជាលទ្ធផលនៅ គឃ/សប ។ នៅថ្នាក់ គជ/ខប នៅពេលដែលសម្ភារឯកសារបោះឆ្នោតបញ្ជូនពីគ្រប់ឃុំ សង្កាត់ទៅដល់រាជធានី ខេត្ត គជ/ខប រៀបចំមជ្ឈមណ្ឌលមួយ ដើម្បីត្រួតពិនិត្យមើលលទ្ធផលនៃការបោះឆ្នោតពីគ្រប់ឃុំសង្កាត់ចំណុះរាជធានី ខេត្តរបស់ខ្លួន ។ ក្នុងការត្រួតពិនិត្យនេះ គាត់ត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលចូលរួម ដើម្បីត្រួតពិនិត្យមើលទៅតាមនីតិវិធី ក្នុងករណីមានបណ្តឹង ឬគ្មានបណ្តឹង គឺគាត់ត្រូវត្រួតពិនិត្យសម្ភារទាំងអស់នេះ និងលទ្ធផលទាំងអស់នេះ ហើយបន្ទាប់មកទៀត គាត់ត្រូវធ្វើការកំណត់បែងចែកអាសនៈដល់គណបក្សនយោបាយដែលជាប់ឆ្នោត និងកំណត់បេក្ខជនជាប់ឆ្នោតដើម្បីបិទផ្សាយនៅឯ គជ/ខប ។ បន្ទាប់មក គជ/ខប បញ្ជូនឯកសារទាំងអស់នេះមក គ.ជ.ប ។ នៅពេលទទួលបានសម្ភារឯកសារទាំងអស់នេះ គ.ជ.ប ត្រូវបង្កើតមជ្ឈមណ្ឌលដើម្បីត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត

នេះ ហើយព្រមទាំងប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត ។ សូមជម្រាបដែរថា នៅ គ.ជ.ប នៅថ្ងៃបោះឆ្នោតតែម្តង គឺយើងមានយន្តការមួយ គឺប្រមូលលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតមកពី គឃ/សប មក គជ/ខប និងមក គ.ជ.ប ហើយ គ.ជ.ប នឹងធ្វើការប្រកាសលទ្ធផលបឋមនៃការបោះឆ្នោតចាប់ពីល្ងាចនៃថ្ងៃបោះឆ្នោតនេះមក ។

***សំណួរ ៖ ចំពោះការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣នេះ ត្រូវបានកែលម្អដូចម្តេចខ្លះ ហើយមានចំណុចខុសគ្នាដូចម្តេចដែរ បើយើងប្រៀបធៀបទៅនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកមុន ក៏ដូចជាការបោះឆ្នោតជាសកលមុនៗដែរ ?***

ចម្លើយ ៖ សូមអរគុណ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣នេះ បើប្រៀបធៀបទៅនឹងការបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ២០០៧ ឬក៏ប្រៀបធៀបនឹងការបោះឆ្នោតសកលមុនៗ មានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ យើងបានធ្វើការកែលម្អមួយចំនួន ក្នុងនោះសំខាន់ការកែលម្អក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គឺច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានធ្វើវិសោធនកម្មនៅក្នុងចំណុចនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដោយបានបន្ថែមរយៈពេលនៃការចុះឈ្មោះបោះឆ្នោតផ្ទាល់នៅឃុំ សង្កាត់ រហូតដល់ ៣០ថ្ងៃ និងបន្ថែមរយៈពេលនៃការប្តឹងតវ៉ាទៅលើបញ្ជីដំបូង ០៥ថ្ងៃទៀត ដែលមានរយៈពេលសរុប ១០ថ្ងៃ ។ ហើយការកែលម្អនេះគឺផ្អែកទៅលើសភាពជាក់ស្តែង និងអនុសាសន៍របស់គណបក្សនយោបាយ ក៏ដូចជាអ្នកសង្កេតការណ៍បោះឆ្នោត ដែលបានផ្តល់អនុសាសន៍ពីក្រោយការបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ២០០៧ ក៏ដូចការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០០៨ ។ នេះជាចំណុចទី១ ទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ ហើយទី២ ទាក់ទងទៅនឹងលិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់ការបោះឆ្នោត កន្លងមក គ.ជ.ប បានសហការជាមួយក្រសួងមហាផ្ទៃ អនុញ្ញាតឱ្យប្រើប្រាស់ទម្រង់ ១០១៨ ដើម្បីផ្តល់ជូនប្រជាពលរដ្ឋដែលខ្វះឯកសារបញ្ជាក់អត្តសញ្ញាណ មេឃុំ ចៅសង្កាត់ ចេញទម្រង់នេះដល់ប្រជាពលរដ្ឋ ដើម្បីចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោតនៅពេលដែលគាត់ធ្វើឱ្យបាត់បង់ឯកសារបញ្ជាក់អត្តសញ្ញាណដើម្បីបោះឆ្នោត ។ ប៉ុន្តែការប្រើប្រាស់ទម្រង់ ១០១៨ កន្លងមកគឺមានជួបបញ្ហា ។ ដូចនេះទម្រង់ ១០១៨ ត្រូវបានមោឃភាពចោលឈប់ប្រើប្រាស់ ហើយក្រសួងមហាផ្ទៃនិង គ.ជ.ប បានចេញនូវទម្រង់ថ្មី ហៅថា ទម្រង់បញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ដែលបានផ្តល់ជូនប្រជាពលរដ្ឋក្នុងដំណាក់កាលចុះឈ្មោះឆ្នាំ២០១១ កន្លងមក ហើយទម្រង់នេះ យើងរៀបចំតាមលក្ខណៈបច្ចេកទេសខ្ពស់ ដែលមានរក្សាការសម្ងាត់ និងសុវត្ថិភាពព្រមទាំងអាចត្រួតពិនិត្យបាននូវការចេញ និងការប្រើប្រាស់ទម្រង់នេះ ។ នេះជាចំណុចថ្មីទី២ ដែលយើងអនុវត្តក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នេះ ។ ហើយដោយឡែកយើងក៏បានកែលម្អនីតិវិធីមួយចំនួនទៀត ឧទាហរណ៍ថ្មីៗនេះ គ.ជ.ប បានចេញនូវនីតិវិធីបំពេញបេក្ខជនបន្ថែមនៅតាមឃុំ សង្កាត់ ក្នុងករណីដែលក្រោយពីការបោះឆ្នោតទៅ គណបក្សដែលជាប់ឆ្នោតពុំមានបេក្ខជនគ្រប់គ្រាន់ទៅតាមចំនួនអាសនៈដែលខ្លួនទទួលបាន ។ នេះជាចំណុចថ្មីមួយ ដែលពីមុនមកមិនទាន់មាន ហើយក្រៅពីហ្នឹងក៏មាននីតិវិធីសំខាន់ៗមួយចំនួននៅក្នុងការអនុវត្តជាក់ស្តែង ជាពិសេសក្នុងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ហើយការកែលម្អទាំងអស់នេះគឺយើងផ្អែកជាសំខាន់ទៅលើអនុសាសន៍ និងបទពិសោធន៍ដែលយើងទទួលបានពីការបោះឆ្នោតមុនៗកន្លងមក ៕

# ភ្នាក់ងារនៃគណបក្សនយោបាយចំនួន ១១៨.៨១០ នាក់ នឹងសង្កេតមើលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២

សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ភ្នាក់ងារនៃគណបក្សនយោបាយសរុបចំនួន **១១៨.៨១០**នាក់ នឹងចូលរួមសង្កេតមើលការបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោត **១៨.១០៧** ការិយាល័យទូទាំងប្រទេស ។



ភ្នាក់ងារនៃគណបក្សនយោបាយចូលរួមសង្កេតមើលដំណើរការបោះឆ្នោតនាពេលកន្លងមក

ចំនួនភ្នាក់ងារទាំងនេះមកពីគណបក្សនយោបាយចំនួន ១០ ដែលគណបក្សនីមួយៗបានដាក់ភ្នាក់ងាររបស់ខ្លួន ដូចខាងក្រោម ៖

១. គណបក្សប្រជាជនកម្ពុជា បានដាក់ភ្នាក់ងារចំនួន **៣៦.១១២**នាក់ ក្នុងនោះស្រីចំនួន **៩.៣៦៩**នាក់។

២. គណបក្ស សម រង្ស៊ី បានដាក់ភ្នាក់ងារចំនួន **៣៤.១២៥**នាក់ ក្នុងនោះស្រីចំនួន **១០.៣០៣**នាក់។

៣. គណបក្សហ៊្វុនស៊ិនប៉ិច បានដាក់ភ្នាក់ងារចំនួន **២០.៧៦៨**នាក់ ក្នុងនោះស្រីចំនួន **៧.៤៨១**នាក់។

៤. គណបក្សសិទ្ធិមនុស្ស បានដាក់ភ្នាក់ងារចំនួន **១៦.៤២១**នាក់ ក្នុងនោះស្រីចំនួន **៣.៩៨១**នាក់។

៥. គណបក្សនរោត្តម រណឫទ្ធិ បានដាក់ភ្នាក់ងារចំនួន **៩.៧៦៧**នាក់ ក្នុងនោះស្រីចំនួន **៣.២០៧** នាក់ ។

៦. គណបក្សសញ្ជាតិកម្ពុជា បានដាក់ភ្នាក់ងារចំនួន **៧៧៨**នាក់ ក្នុងនោះស្រីចំនួន **៣១៣**នាក់ ។

៧. គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានដាក់ភ្នាក់ងារចំនួន **៤៥៩**នាក់ ក្នុងនោះស្រីចំនួន **១០៥** នាក់ ។

៨. គណបក្សខ្មែរឈប់ក្រ បានដាក់ភ្នាក់ងារចំនួន **៣០៥**នាក់ ក្នុងនោះស្រីចំនួន **១០៨**នាក់ ។

៩. គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ បានដាក់ភ្នាក់ងារចំនួន **៦៣**នាក់ ក្នុងនោះស្រីចំនួន **២២**នាក់។

១០. គណបក្សចលនាប្រជាធិបតេយ្យបានដាក់ភ្នាក់ងារចំនួន **១២**នាក់ ។/


## ក្រុមរៀបចំព្រឹត្តិបត្រព័ត៌មាន គ.ជ.ប

**អ្នកគ្រប់គ្រង**

លោក មៃ សារី

**ក្រុមនិពន្ធ**

លោក មិន ពុធជេដ្ឋាវណ្ណ លោក សុខ លាត

លោក ទិន ករុណា

**កំណែអក្ខរាវិរុទ្ធ**

អ្នកស្រី ទិន សាវត្ថី

**អ្នកថតរូប**

លោក សាក់ បូរិន លោក គឹម យុង

លោក រិន វុទ្ធី

**ក្រាហ្វិកកុំព្យូទ័រ**

លោក ប៉េង រតនៈ លោក ចាន់ វិបុល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ៤៧៥/១៧ **គ.ជ.ប**

**សេចក្តីណែនាំរំលឹក**
**ស្តីពី**
**ការផ្សព្វផ្សាយ និងការអត្ថាធិប្បាយព័ត៌មាន**

**យោង** : - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣

ក្នុងការឃោសនាបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ចាប់តាំងពីថ្ងៃចាប់ផ្តើមរហូតមកដល់ពេលនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សង្កេតឃើញថា គណបក្សនយោបាយ បេក្ខជន និងអ្នកគាំទ្រ អង្គការ និងប្រព័ន្ធផ្សព្វផ្សាយភាគច្រើនបានអនុវត្តត្រឹមត្រូវតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី ក្រមសីលធម៌ និងគោលការណ៍នៃការឃោសនាបោះឆ្នោត ហើយសកម្មភាពនៃការឃោសនាទូទៅ ប្រព្រឹត្តដោយល្អប្រសើរ ប៉ុន្តែក៏នៅមានមជ្ឈដ្ឋាន និងបុគ្គលមួយចំនួនមិនបានគោរព និងអនុវត្តបានត្រឹមត្រូវនៅឡើយ។ គ.ជ.ប សូមណែនាំរំលឹកដល់គណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រ អង្គការសង្កេតការណ៍ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ ដូចខាងក្រោម ៖

១. គណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រ អង្គការសង្កេតការណ៍បោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ត្រូវយកចិត្តទុកដាក់គោរព និងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ក្រមសីលធម៌ គោលការណ៍នៃការឃោសនាបោះឆ្នោត និងគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

២. អ្នកយកព័ត៌មាន អ្នករាយការណ៍ និងអ្នកធ្វើអត្ថាធិប្បាយ ត្រូវជៀសវាងសម្តែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថតាមរយៈការលើកដាក់សំឡេង ឬឥរិយាបថជាក់ស្តែងផ្សេងទៀត។

៣. ក្នុងដំណាក់កាលឃោសនាបោះឆ្នោតនេះ ការផ្សព្វផ្សាយណាមួយដែលមិនអនុវត្តតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី និងសេចក្តីណែនាំរំលឹកនេះ គ.ជ.ប នឹងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

ទទួលបានសេចក្តីណែនាំរំលឹកនេះ គ.ជ.ប សង្ឃឹមថា គណបក្សនយោបាយ ឬ/និងបេក្ខជន ឬអ្នកគាំទ្រ អង្គការសង្កេតការណ៍បោះឆ្នោត និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីឲ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០១២
**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

អ៊ឹម សួស្តី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០១ សណន**

**សេចក្តីណែនាំ**

**ស្តីពី**

**ការហាមឃាត់មិនឱ្យលក់ដូរ និងពិសារគ្រឿងស្រវឹងមួយថ្ងៃមុនថ្ងៃបោះឆ្នោត**
**និងថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣**
**ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១២**

ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១២ ខាងមុខនេះ ព្រះរាជាណាចក្រកម្ពុជា នឹងមានការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣ ដែលរៀបចំឡើងដោយកម្ពុជាខ្លួនឯងផ្ទាល់ ។ អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ ស្តីពីវិសោធនកម្ម នៃច្បាប់នេះ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ គ្មានអំពើហិង្សា គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ និងបាតុភាពនានា ដែលអាចកើតមានឡើង ដោយសារការប្រើប្រាស់គ្រឿងស្រវឹងនោះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម ៖

១-ប្រជាពលរដ្ឋខ្មែរ និងជនបរទេសទាំងអស់ ដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរួមសហការជាមួយរាជរដ្ឋាភិបាល កងកម្លាំងសន្តិសុខគ្រប់ប្រភេទ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដោយត្រូវផ្អាកពិសារ និងផ្អាកការលក់ដូរគ្រឿងស្រវឹងមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត គឺចាប់ពីម៉ោង ២៤ នៃថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១២ រហូតដល់ម៉ោង ២៤ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១២ ដើម្បីរួមចំណែកទប់ស្កាត់អំពើហិង្សា ការគំរាមកំហែង ការបំភិតបំភ័យ និងបាតុភាពនានា ដែលអាចបណ្តាលមកពីការពិសារគ្រឿងស្រវឹងគ្រប់ប្រភេទ ។

២-កងរាជអាវុធហត្ថ កងនគរបាលជាតិ រួមជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើការបំពាក់បំប៉នដល់កងកម្លាំង និងមន្ត្រីរាជការក្រោមឱវាទ និងអប់រំណែនាំប្រជាពលរដ្ឋខ្មែរ និងជនបរទេស ទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួន អនុវត្តផ្អាកការលក់ដូរ និងពិសារគ្រឿងស្រវឹង ក្នុងគោលបំណងធ្វើឱ្យកិច្ចដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១២ ខាងមុខនេះ ប្រព្រឹត្តទៅក្នុងបរិយាកាសនយោបាយល្អ សេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សា ។

-9-

៣-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពត៌មាន ត្រូវសហការជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធ្វើការផ្សព្វផ្សាយសេចក្តីណែនាំនេះ ជូនដល់ប្រជាពលរដ្ឋខ្មែរជនបរទេស អ្នកលក់ដូរ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធជាតិទាំងមូល ឱ្យបានយល់ជ្រួតជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាព ។

រាជរដ្ឋាភិបាលសង្ឃឹមជឿជាក់ថា ពេលទទួលបានសេចក្តីណែនាំនេះ អាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងប្រជាពលរដ្ឋខ្មែរជនបរទេស និងអ្នកលក់ដូរទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងចូលរួមអនុវត្ត សេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីធ្វើឱ្យកិច្ចដំណើរការបោះឆ្នោតនេះ ទទួលបានលទ្ធផលល្អប្រសើរ ជូនជាតិ និងមាតុភូមិ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

---

តមកពីទំព័រទី ២ **សន្និសីទសារព័ត៌មាន...**






សកម្មភាពឃោសនារបស់គណបក្សនយោបាយមួយចំនួន

ផ្នែកនយោបាយ មិនត្រូវបង្កើតបញ្ហាតូចឱ្យទៅជាបញ្ហាធំ បើមានបញ្ហាអ្វីសូមលើកឱ្យចំបញ្ហា ដើម្បីឱ្យ គ.ជ.ប មានវិធានការនិងដោះស្រាយ ។ គ.ជ.ប មានសមត្ថកិច្ចពេញលេញស្របតាមច្បាប់ក្នុងការរៀបចំការបោះឆ្នោត និងការអនុវត្តច្បាប់ ។ គ.ជ.ប បានធ្វើប្រតិភូកម្មអំណាចទៅថ្នាក់ក្រោម ដើម្បីចាត់ចែងការងារតាមនីតិវិធីដែលច្បាប់បានកំណត់ មិនមែនមានន័យថា គ.ជ.ប គ្មានសមត្ថកិច្ចទេ ។ ចំពោះការប្តឹងតវ៉ា គណបក្សនយោបាយមានសិទ្ធិប្តឹងទៅតាមនីតិវិធីច្បាប់ បើគាត់មិនសុខចិត្តទៅនឹងការសម្រុះសម្រួលនៅនឹងកន្លែងកើតហេតុ ហើយច្បាប់បានកំណត់អំពីថេរវេលាប្តឹង និងពេលដោះស្រាយ ។ ការដោះស្រាយនៅថ្នាក់ គឃ/សប ត្រូវធ្វើឡើងយ៉ាងដូចម្តេច នៅថ្នាក់ គជ/ខប និង គ.ជ.ប ត្រូវធ្វើដូចម្តេច ដែលនីតិវិធីនេះសុទ្ធតែមានចែងក្នុងច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី ។

នៅក្នុងសន្និសីទនោះ មានតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មានចូលរួមប្រមាណ ៤៥នាក់ ៕

គ.ជ.ប

# គណបក្សនយោបាយដែលចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

## ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២

| | |
|---|---|
| គណបក្សប្រជាជនកម្ពុជា | ប្រ.ជ |
| គណបក្ស សម រង្ស៊ី | គ.ស.រ. |
| គណបក្សហ្វ៊ុនស៊ិនប៉ិច | រ.រ.ជ.ក.ឯ.អ.ស.ស |
| គណបក្ស សិទ្ធិមនុស្ស | គ.ស.ម. |
| គណបក្ស នរោត្តម រណឫទ្ធិ | គ.ន.រ |
| គណបក្ស សញ្ជាតិកម្ពុជា | គ.ស.ក |
| គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | គ.ស.ប |
| គណបក្សខ្មែរឈប់ក្រ | គ.ខ.ឈ.ក |
| គណបក្សសាធារណរដ្ឋ ប្រជាធិបតេយ្យ | គ ស រ ប |
| គណបក្សចលនាប្រជាធិបតេយ្យ | គ ច ប |

**នេះមិនមែនជាសន្លឹកឆ្នោតទេ**